# ខ្លឹមសារសង្ខេបអត្ថបទ
# ការជូនដំណឹងអំពីបទចោទ

Johann Bair, The International Covenant on Civil and Political Rights and Its (First) Optional Protocol, A Short Commentary Based on Views, General Comments and Concluding Observations by the Human Rights Committee, pp. 62-63, 2005

**បទប្បញ្ញត្តិ៖** *មាត្រា១៤ (៣.ក) នៃកតិកាសញ្ញា៖ ៣.ក្នុងការសម្រេចសេចក្តីចោទប្រកាន់ពីបទ ព្រហ្មទណ្ឌណាមួយប្រឆាំងមកលើខ្លួន ជនគ្រប់រូបមានសិទ្ធិទទួលបានការធានាជាអប្បបរិមា ដោយស្មើភាពគ្នាយ៉ាងពេញលេញ ដូចខាងក្រោម៖ (ក) ត្រូវបានព័ត៌មានភ្លាមៗ និងដោយលំអិតអំពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់មកលើខ្លួនជាភាសាដែលជននោះចេះ ។..*

**១.** ការជូនដំណឹងនេះ ត្រូវធ្វើឡើងក្នុងភាសាដែលអាចយល់បាន អំពីប្រភេទចោទប្រកាន់ ភ្លាមៗ ទោះបីជាជនជាប់ចោទនៅក្នុង ឬក្រៅឃុំក្តី នៅក្រោយពេលដែលជំហាននីតិវិធី ត្រូវបានចាប់ផ្តើម ឬឈ្មោះរបស់ជនសង្ស័យត្រូវបានផ្សព្វផ្សាយជាសាធារណៈ ។ ការជូនដំណឹង អាចក្នុងទម្រង់ផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សរ ។ ការទាមទារនូវភាពបន្ទាន់នេះ គឺដោយសារថា ការពន្យាពេល នឹងនាំឱ្យប៉ះដល់សិទ្ធិការពារខ្លួន ។

**២.** ការទាមទារជូនដំណឹងភ្លាមនេះ អនុវត្តសម្រាប់ករណី ដែលជនសង្ស័យត្រូវ បានចោទប្រកាន់ជាផ្លូវការ ក្នុងសំណុំរឿងព្រហ្មទណ្ឌ មិនអនុវត្តសម្រាប់ករណីការឃាត់ខ្លួនរង់ចាំលទ្ធផលស៊ើបអង្កេត របស់ប៉ូលីស ដែលមាត្រា ៩(២) នឹងអនុវត្ត ។